ACRA
ASSOCIATION OF CAMBODIAN RECRUITMENT AGENCIES

MANPOWER ASSOCIATION OF CAMBODIA



# ក្រមសីលធម៌

## សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាសេនាធិការ មានសេចក្តីសោមនស្សរីករាយ សូមប្រកាសគាំទ្រចំពោះ សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា (ACRA) និង សមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា (MAC) ដែលបានអភិវឌ្ឍនិងដាក់ឱ្យប្រើប្រាស់ក្រមសីលធម៌នេះឡើង។ ដោយមានការគាំទ្រជំនួយបច្ចេកទេស និងកិច្ចសហប្រតិបត្តិការពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គការអន្តរជាតិខាងការងារ (ILO) សមាគម ACRA និងសមាគម MAC បានបោះពុម្ពក្រមសីលធម៌នេះឡើងដើម្បីផ្សព្វផ្សាយ និងបង្កើនការយល់ដឹងស្តីពីការជ្រើសរើសពលករប្រកបដោយយុត្តិធម៌ដល់ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត។ គោលការណ៍គ្រឹះសំខាន់ៗដែលបានគូសបញ្ជាក់នៅក្នុងឯកសារក្រមសីលធម៌នេះ បានឆ្លុះបញ្ចាំងពីការតាំងចិត្តយ៉ាងពិតប្រាកដរបស់សមាគម ACRA និងសមាគម MAC ក្នុងការអនុវត្តក្រមសីលធម៌នេះប្រកបដោយក្រមសីលធម៌យ៉ាងខ្ជាប់ខ្ជួន រួមទាំងការទទួលខុសត្រូវខ្ពស់ និងជានាដល់និរន្តរភាពប្រតិបត្តិការអាជីវកម្មរបស់ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ផងដែរ។

ក្រមសីលធម៌នេះមានសារៈសំខាន់ណាស់ ដើម្បីជានាការធ្វើទេសន្តរប្រវេសន៍ការងាររបស់ពលករទទួលបានលទ្ធផលជោគជ័យ និងបទពិសោធន៍ជាវិជ្ជមាន ក៏ដូចជាទទួលបាននូវការការពារសិទ្ធិ និងគាំទ្រដល់ពួកគេក្នុងការរួមចំណែកដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាប័ន្ន សម្រាប់ពលករផ្ទាល់ខ្លួន សមាជិកគ្រួសារ សហគមន៍ និងប្រទេសជាតិទាំងមូល។

ក្រមសីលធម៌នេះគឺជាឧបករណ៍មួយដែលអាចអនុវត្តបានដោយទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជាទាំងអស់។ ក្រមសីលធម៌នេះបានដាក់ចេញនូវគោលការណ៍គ្រឹះជាមូលដ្ឋានស្របតាមច្បាប់ជាតិ និងបទដ្ឋានការងារអន្តរជាតិ សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជាទាំងអស់អនុវត្តប្រកបដោយប្រសិទ្ធភាព ការទទួលខុសត្រូវនិងគោរពក្រមសីលធម៌ខ្ពស់ក្នុងការគ្រប់គ្រងការជ្រើសរើស ការបណ្តុះបណ្តាល ការបញ្ជូន និងការគ្រប់គ្រងពលករទៅធ្វើការនៅក្រៅប្រទេស។ ក្រមសីលធម៌នេះនឹងរួមចំណែកពង្រឹងប្រសិទ្ធភាពនៃការការពារ ការលើកកំពស់សិទ្ធិការងារ ក៏ដូចជាសុខុមាលភាពរបស់ពលករទាំងនៅក្នុងស្រុក និងនៅបរទេស។ លើសពីនេះទៀត ក្រមសីលធម៌នេះនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការ គាំទ្រការអនុវត្តរបស់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជាប្រកបដោយគណនេយ្យភាពផង ហើយក៏ជាប្រភពដែលមានសារៈប្រយោជន៍ សម្រាប់ពលករទេសន្តរប្រវេសន៍អាចបញ្ជាក់បានអំពីការរំពឹងទុករបស់ពលករពីទីភ្នាក់ងារជ្រើសរើសឯកជន ដែលទាក់ទងទៅនឹងបទពិសោធន៍ទេសន្តរប្រវេសន៍ការងាររបស់ពួកគេ។

ខ្ញុំសូមសម្តែងនូវសេចក្តីថ្លែងអំណរគុណ ចំពោះភាគីទាំងអស់ដែលបានចូលរួមអភិវឌ្ឍក្រមសីលធម៌នេះឡើង ជាពិសេសអង្គការអន្តរជាតិខាងការងារ (ILO) ដែលបានផ្តល់កិច្ចសហប្រតិបត្តិការ និងជំនួយបច្ចេកទេសដ៏មានសារៈសំខាន់តាមរយៈកម្មវិធីត្រីកោណក្នុងតំបន់អាស៊ាន។

លើសពីនេះខ្ញុំសូមអបអរសាទរសមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា ACRA និងសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា MAC ចំពោះកិច្ចសហការដ៏ល្អក្នុងដំណើរការកិច្ចពិគ្រោះយោបល់ដែលបានរៀបចំឡើងជាច្រើនលើកច្រើនសាររវាងមន្ត្រីជំនាញរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាមួយតំណាងឱ្យទីភ្នាក់ងារជ្រើសរើសឯកជន តំណាងសមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា តំណាងសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា និងអ្នកឯកទេសរបស់អង្គការអន្តរជាតិខាងការងារ (ILO)។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រៀមខ្លួនជានិច្ចក្នុងការផ្តល់ការគាំទ្រដល់សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា ACRA និងសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា MAC ក្នុងការអនុវត្តក្រមសីលធម៌នេះ ឱ្យបានពេញលេញប្រកបដោយប្រសិទ្ធភាពខ្ពស់ ដើម្បីលើកកំពស់ និងការការពារសិទ្ធិពលករទេសន្តរប្រវេសន៍គ្រប់រូបទទួលបានសេវាយុត្តិធម៌។

ថ្ងៃព្រហស្បតិ៍ ៨កើត ខែ បុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែមករា ឆ្នាំ២០២០

**អ៊ិត សំហេង**

រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# ១ សេចក្តីផ្តើម

ការកើនឡើងនៃចំនួនពលករទេសន្តរប្រវេសន៍ និងបទពិសោធន៍ជាវិជ្ជមានរបស់ពលករទេសន្តរប្រវេសន៍កម្ពុជា គឺជាអាទិភាពមួយរបស់រាជរដ្ឋាភិបាលកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចាត់ទុកថា ទេសន្តរប្រវេសន៍ការងារបានរួមចំណែកយ៉ាងសំខាន់ដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាបន្នរបស់ប្រទេសកម្ពុជា ជាពិសេសបានរួមចំណែកកាត់បន្ថយភាពក្រីក្រ និងធ្វើឱ្យជីវភាពរបស់ប្រជាពលរដ្ឋបានកាន់តែប្រសើរឡើង។ នៅក្នុងបរិបទនេះទេសន្តរប្រវេសន៍ការងារអាចផ្តល់ផលប្រយោជន៍ដល់ពលករ និងក្រុមគ្រួសាររបស់ពួកគេ ព្រមទាំងប្រទេសជាតិទាំងមូល។

អស់រយៈពេលជាច្រើនឆ្នាំកន្លងមកនេះ ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា បាននឹងកំពុងបន្តជ្រើសរើស និងផ្តល់ការបណ្តុះបណ្តាលដល់ពលករ ដើម្បីជាជម្រើសឱ្យពួកគេទទួលបានឱកាសការងារសមរម្យនៅក្រៅប្រទេស។ ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងការលើកកម្ពស់ជីវភាពរស់នៅរបស់ពលករទេសន្តរប្រវេសន៍រួមទាំងគ្រួសាររបស់ពួកគេ និងសង្គមជាតិទាំងមូល។

ដើម្បីធានាឱ្យមានការទទួលខុសត្រូវកាន់តែខ្ពស់ រួមនិងការអនុវត្តការជ្រើសរើសពលករប្រកបដោយយុត្តិធម៌ និងការគាំទ្រអភិវឌ្ឍន៍អាជីវកម្មប្រកបដោយនិរន្តរភាព និងបន្តកសាងកេរ្តិ៍ឈ្មោះកាន់តែល្អប្រសើរ និងកិត្តិសព្ទជាវិជ្ជមានរបស់ទីភ្នាក់ងារជ្រើសរើសឯកជនថែមទៀត សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា(ACRA)និងសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា (MAC) បានអភិវឌ្ឍន៍ និងដាក់ឱ្យអនុវត្តក្រមសីលធម៌នេះឡើងក្នុងគោលបំណងដើម្បីលើកកម្ពស់ការជ្រើសរើសពលករប្រកបដោយយុត្តិធម៌តាមរយៈ កិច្ចសហការ និងទទួលបានការគាំទ្របច្ចេកទេសពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គការអន្តរជាតិខាងការងារ។ ក្រមសីលធម៌នេះត្រូវអនុវត្តដោយទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា ដើម្បីធានាដល់ការគ្រប់គ្រងពលករប្រកបដោយប្រសិទ្ធិភាព នៅក្នុងដំណាក់កាលនៃការជ្រើសរើស ការបណ្តុះបណ្តាល ការបញ្ជូន និងគ្រប់គ្រងពលករទៅធ្វើការងារនៅបរទេស។ ក្រមសីលធម៌នេះនឹងដើរតួនាទីយ៉ាងសំខាន់ ដើម្បីធានានូវគណនេយ្យភាព ដោយតម្រូវឱ្យទីភ្នាក់ងារជ្រើសរើសឯកជនអនុវត្ត ស្របតាមច្បាប់ជាតិ និងបទដ្ឋានការងារអន្តរជាតិ។ តាមរយៈការអនុវត្តក្រមសីលធម៌នេះ នឹងធ្វើឱ្យកាន់តែល្អប្រសើរឡើងថែមទៀតនៃបទពិសោធការងារនៅក្រៅប្រទេសរបស់ពលករ និងផ្តល់ផលប្រយោជន៍ដល់ពលករទេសន្តរប្រវេសន៍កម្ពុជា រួមទាំងការការពារ ការលើក

កម្ពស់សិទ្ធិរបស់ពួកគេ រួមទាំងផ្តល់នូវផលប្រយោជន៍យ៉ាងធំធេងដល់ការអភិវឌ្ឍអាជីវកម្មរបស់ទីភ្នាក់ងារជ្រើសរើសឯកជនទាំងនេះ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានធ្វើការកោតសរសើរ និងវាយតម្លៃខ្ពស់ដល់ការអភិវឌ្ឍក្រមសីលធម៌នេះឡើង និងដាក់ឱ្យអនុវត្តក្រមសីលធម៌នេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លើកទឹកចិត្តដល់ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ចូលរួមអនុវត្តក្រមសីលធម៌នេះឱ្យបានពេញលេញ ដើម្បីឱ្យទទួលបានលទ្ធផលកាន់តែល្អប្រសើរសម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនផង និងពលករផងដែរ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចាត់ទុកការអនុវត្តក្រមសីលធម៌នេះ ជាសុចនាករមួយដ៏សំខាន់ សម្រាប់ធ្វើការវាយតម្លៃ និងចំណាត់ថ្នាក់ដល់ការបំពេញការងាររបស់ទីភ្នាក់ងារជ្រើសរើសឯកជន។ នេះក៏ជាឱកាសសមស្របផងដែរ សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ បន្តការអនុវត្តការងាររបស់ខ្លួនឱ្យកាន់តែប្រសើរឡើងថែមទៀត តាមរយៈការអនុវត្តក្រមសីលធម៌នេះ ទីភ្នាក់ងារជ្រើសរើសឯកជនពិតជាមានសក្តានុពលខ្ពស់ ដែលអាចពង្រីកវត្តមានរបស់ខ្លួនបានទាំងក្នុងប្រទេស និងលើឆាកអន្តរជាតិជាក់ជាមិនខាន។

សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា (ACRA) និងសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា (MAC) គឺជាសមាគមវិជ្ជាជីវៈនៃទីភ្នាក់ងារជ្រើសរើសឯកជននៅព្រះរាជាណាចក្រកម្ពុជា។ គោលដៅរបស់សមាគមទាំងពីរ ធានាយ៉ាងណាដល់ទីភ្នាក់ងារជ្រើសរើសឯកជនអាចបន្តចូលរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍជំនាញ សង្គម សេដ្ឋកិច្ច ព្រមទាំងបន្តពង្រីកទីផ្សារថ្មីៗបន្ថែមទៀតសម្រាប់សមាជិករបស់សមាគមទាំងពីរ តាមរយៈការបន្តកិច្ចសហការជាមួយរដ្ឋាភិបាល និយោជកនិងកម្មករនិយោជិត។ លើសពីនេះ សមាគមទាំងពីរប្តេជ្ញាចិត្តបន្តធ្វើកិច្ចសហការជាមួយនឹងអង្គការវិជ្ជាជីវៈ និងស្ថាប័នពាក់ព័ន្ធនានា ដើម្បីធានាដល់ការផ្សព្វផ្សាយបង្កើនការយល់ដឹង និងចូលរួមអនុវត្តក្រមសីលធម៌ ក៏ដូចជាការលើកកម្ពស់ការអនុវត្តការជ្រើសរើសពលករប្រកបដោយភាពយុត្តិធម៌របស់ទីភ្នាក់ងារជ្រើសរើសឯកជន។ នេះជាភារកិច្ចសំខាន់ៗដើម្បីការពារ និងលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍កម្ពុជា។ ក្រមសីលធម៌នេះនឹងជួយគាំទ្រឧត្តមភាព កេរ្តិ៍ឈ្មោះរបស់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា ទាំងនៅក្នុងប្រទេស ក្នុងតំបន់ និងលើឆាកអន្តរជាតិយ៉ាងពិតប្រាកដផងដែរ។

សមាគម ACRA និង សមាគម MAC សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការគាំទ្ររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ដែលជាសមាជិករបស់សមាគមទាំងពីរ និងកម្មវិធីត្រីកោណក្នុងតំបន់អាស៊ាន TRIANGLE in ASEAN របស់

អង្គការអន្តរជាតិខាងការងារ ដែលបានធ្វើកិច្ចសហប្រតិបត្តិការ និងផ្តល់ជំនួយបច្ចេកទេសសម្រាប់ការរៀបចំក្រមសីលធម៌នេះឡើង។



**លោកជំទាវ ឧកញ៉ា អ៊ឹង ស៊ាងរិទ្ធី**

**ប្រធានសមាគម** ACRA



**អន ប៊ុនហាក់**

**ប្រធានសមាគម** MAC

## ២ និយមន័យ និងពាក្យគន្លឹះមួយចំនួន ដែលប្រើប្រាស់ក្នុងក្រមសីលធម៌នេះ៖

- **ពលកម្មកុមារ** សំដៅលើការងារទាំងឡាយណាដែលធ្វើឱ្យកុមារបាត់បង់កុមារភាព សក្តានុពល និងសេចក្តីថ្លៃថ្នូររបស់ពួកគេ និងដែលបង្កគ្រោះថ្នាក់ដល់ការអភិវឌ្ឍកាយសម្បទា និងបញ្ញាស្មារតីរបស់ពួកគេ។ ពលកម្មកុមារ សំដៅលើការងារទាំងឡាយណា ដែលបង្កគ្រោះថ្នាក់ និងអន្តរាយផ្នែកបញ្ញាស្មារតី កាយសម្បទា សង្គម ឬសីលធម៌ ដល់កុមារ និងប៉ះពាល់ដល់ការអប់រំរបស់ពួកគេ។

- **និយោជក** សំដៅលើបុគ្គល ឬស្ថាប័នទាំងឡាយណាដែលជួលនិយោជិត ឬកម្មករដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី។

- **ពលកម្មដោយបង្ខំ** គឺជាទម្រង់មួយនៃបទឧក្រិដ្ឋ។ រាប់បញ្ចូលការងារ ឬសេវាទាំងឡាយណាដែលបុគ្គលម្នាក់ត្រូវធ្វើក្រោមការគម្រាម ទទួលរងពិន័យ ឬការដាក់ទណ្ឌកម្ម ហើយដែលបុគ្គលនោះពុំបានយល់ព្រមធ្វើដោយសេរីនោះឡើយ។

- **ពលករទេសន្តរប្រវេសន៍** សំដៅលើពលករកម្ពុជា អាយុចាប់ពី ១៨ ឆ្នាំឡើងទៅ ដែលបានដាក់ពាក្យទៅធ្វើការងារនៅក្រៅប្រទេស និងដែលកំពុងស្ថិតក្នុងដំណើរការបំពេញទម្រង់ ឬឯកសារផ្លូវការ តាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន ស្របតាមសេចក្តីណែនាំរបស់ស្ថាប័នមានសមត្ថកិច្ច ដូចជា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងក្រសួងមហាផ្ទៃជាដើម (អនុក្រឹត្យលេខ ១៩០) ដោយរាប់បញ្ចូលទាំង សិក្ខាកាម ឬកម្មសិក្សាការី ដែលស្ថិតនៅក្រោមកម្មវិធីបណ្តុះបណ្តាល ឬកម្មសិក្សាពាក់ព័ន្ធនានា។

- **ទីភ្នាក់ងារជ្រើសរើសពលករឯកជន** សំដៅលើនីតិបុគ្គលឯកជន ដែលត្រូវបានបង្កើតឡើងក្រោមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា និងដែលបានទទួលការអនុញ្ញាតជាផ្លូវការពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីទទួលខុសត្រូវផ្តល់សេវាស្វែងរកការងារធ្វើនៅក្រៅប្រទេស (អនុក្រឹត្យលេខ ១៩០)។

- **ការជ្រើសរើសពលករ** សំដៅ និងរួមមានការផ្សាយពាណិជ្ជកម្ម ការផ្សព្វផ្សាយព័ត៌មានការជ្រើសរើស ការដឹកជញ្ជូន ការផ្តល់ការងារឱ្យធ្វើ និងសម្រាប់ពលករទេសន្តរប្រវេសន៍

ការវិលត្រឡប់មកប្រទេសប្រភពដើមវិញ ទៅតាមការសមស្រប។ ចំណុចនេះអនុវត្តទាំងចំពោះអ្នកស្វែងរកការងារធ្វើផង និងអ្នកដែលស្ថិតនៅក្នុងទំនាក់ទំនងការងារផង។

- **ថ្លៃសេវាជ្រើសរើសពលករ ឬ ថ្លៃចំណាយពាក់ព័ន្ធ** សំដៅលើថ្លៃសេវា ឬចំណាយទាំងឡាយណាដែលកើតឡើងក្នុងដំណើរការនៃការជ្រើសរើសពលករ ដើម្បីឱ្យពលករអាចទទួលបានការងារ ឬសេវាស្វែងរកការងារ ដោយមិនគិតពីលក្ខណៈ ពេលវេលា ឬទីតាំងនៃការកំណត់ ឬការប្រមូលថ្លៃសេវានោះឡើយ។
- **ការជួញដូរមនុស្ស** សំដៅលើការជ្រើសរើស ការបញ្ជូន ការផ្ទេរ ការលាក់បំពួន ឬការទទួលមនុស្សដោយប្រើមធ្យោបាយគំរាមកំហែង ឬប្រើប្រាស់កម្លាំង ឬទម្រង់ផ្សេងទៀត ដូចជាការបង្ខិតបង្ខំ ការចាប់ពង្រត់ ការគៃបន្លំ ការបោកប្រាស់ ការប្រើបំពានអំណាច ឬស្ថានភាពងាយរងគ្រោះ ឬការផ្តល់ ឬទទួលការទូទាត់ ឬអត្ថប្រយោជន៍ ដើម្បីឱ្យបុគ្គលម្នាក់យល់ព្រមដាក់ខ្លួនស្ថិតក្រោមការគ្រប់គ្រងរបស់បុគ្គលម្នាក់ផ្សេងទៀត ក្នុងគោលបំណងកេងប្រវ័ញ្ច ដូចជាការធ្វើអាជីវកម្មពេស្យាចាររបស់អ្នកដទៃទៀត ការកេងប្រវ័ញ្ចផ្លូវភេទ ពលកម្មដោយបង្ខំ អំពើទាសភាព ឬការអនុវត្តស្រដៀងគ្នា និងការដកយកសរីរាង្គកាយជាដើម។
- **ពលករ** សំដៅលើពលរដ្ឋកម្ពុជាដែលស្ថិតនៅក្នុងគ្រប់ដំណាក់កាលនៃទេសន្តរប្រវេសន៍ការងារ ចាប់ពីពេលចុះកិច្ចសន្យាស្វែងរកការងារជាមួយនឹងទីភ្នាក់ងារជ្រើសរើសពលករឯកជន រហូតដល់ពេលដែលពួកគេវិលត្រឡប់មកផ្ទះវិញ។ ពាក្យនេះ ក៏បញ្ចូលពលរដ្ឋកម្ពុជា ដែលឆ្លងកាត់ការហាត់ការ និងធ្វើការងារនៅក្រៅប្រទេស និងមានកិច្ចសន្យាត្រឹមត្រូវ ដែលមានការទទួលស្គាល់ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈផងដែរ (អនុក្រឹត្យលេខ ១៩០)។

# ពាក្យកាត់សម្គាល់ស្ថាប័ន៖

- ACRA៖ សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា
- CoC៖ ក្រមសីលធម៌
- MAC៖ សមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា
- ILO៖ អង្គការអន្តរជាតិខាងការងារ
- MoLVT៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- PRA៖ ទីភ្នាក់ងារជ្រើសរើសឯកជន

## ៣ ក្រមសីលធម៌សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា

**មាន១២មាត្រា**

១. គោរពចំពោះ និងអនុវត្តច្បាប់ជាតិ ព្រមទាំងគោលការណ៍ជាមូលដ្ឋាន និងសិទ្ធិនៅកន្លែងធ្វើការ

២. គោរពចំពោះ លើការទំនាក់ទំនង ភាពច្បាស់លាស់ និងតម្លាភាពក្នុងការផ្សព្វផ្សាយពាណិជ្ជកម្ម

៣. គោរពចំពោះ និងចូលរួមកាត់បន្ថយថ្លៃចំណាយបន្ទាប់បន្សំ និងថ្លៃសេវាសម្រាប់ការធ្វើទេសន្តរប្រវេសន៍

៤. គោរពចំពោះ និងអនុវត្តការជ្រើសរើស នៃកិច្ចសន្យាសេវារកការងារឱ្យធ្វើ និងកិច្ចសន្យាការងារ

៥. គោរពចំពោះ និងការការពារទិន្នន័យ និងការរក្សាការសម្ងាត់

៦. គោរពចំពោះ ការទទួលស្គាល់ជំនាញ និងគុណវុឌ្ឍិវិជ្ជាជីវៈ

៧. គោរពចំពោះ និងការផ្តល់ព័ត៌មានស្តីពីទេសន្តរប្រវេសន៍ និងផ្តល់ការណែនាំតម្រង់ទិស មុនពេលចេញដំណើរជាចាំបាច់

៨. គោរពចំពោះ និងផ្តល់ការដោះស្រាយវិវាទដោយយន្តការទទួលពាក្យបណ្តឹងពលករទេសន្តរប្រវេសន៍

៩. គោរពចំពោះ និងធ្វើប្រតិបត្តិការបញ្ជូនពលករទៅធ្វើការងារនៅក្រៅប្រទេសតែនៅក្នុងកិច្ចព្រមព្រៀងអនុស្សរណៈនៃការយោគយល់គ្នា ( MOU ) ដែលអនុញ្ញាតដោយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ

១០. គោរពចំពោះ និងការការពារសិទ្ធិពលករ ដែលធ្វើការងារនៅប្រទេសគោលដៅ

១១. គោរពចំពោះ និងគាំទ្រការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មពលករទេសន្តរប្រវេសន៍

១២. គោរពចំពោះ និងធ្វើឱ្យមានសុវត្ថិភាព សេរីភាពនៃការបម្លាស់ទីគ្រប់ដំណាក់កាលនៃការធ្វើទេសន្តរប្រវេសន៍

## ១. គោរពចំពោះ និងអនុវត្តច្បាប់ជាតិ ព្រមទាំងគោលការណ៍ជាមូលដ្ឋាន និងសិទ្ធិនៅកន្លែងធ្វើការ

១.១ ទីភ្នាក់ងារជ្រើសរើសឯកជន ត្រូវគោរពតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តិ កិច្ចព្រមព្រៀងពហុភាគី និងទ្វេភាគីដែលកំពុងចូលជាធរមានទាំងអស់ពាក់ព័ន្ធនឹងទេសន្តរប្រវេសន៍ការងារ ព្រមទាំងគោលនយោបាយ ពាក់ព័ន្ធនឹងការជ្រើសរើសពលករទេសន្តរប្រវេសន៍ ក្នុងយុត្តាធិការនៃប្រទេសប្រភពដើម ប្រទេសឆ្លងកាត់ និងប្រទេសគោលដៅរួមនឹងច្បាប់ លិខិតបទដ្ឋានគតិយុត្តិ កិច្ចព្រមព្រៀង និងគោលនយោបាយពាក់ព័ន្ធនឹងការធ្វើទេសន្តរប្រវេសន៍ការងាររបស់ពលករទេសន្តរប្រវេសន៍។ គោលការណ៍នេះហាមឃាត់យ៉ាងដាច់ខាតមិនឱ្យមានការប្រើប្រាស់ការជួញដូរមនុស្ស ពលកម្មដោយបង្ខំ ពលកម្មកុមារ និងបញ្ចូលការគោរពសិទ្ធិសេរីភាពនៃការបង្កើតអង្គការវិជ្ជាជីវៈ និងការចរចាជាសមូហភាព ការគោរពសមភាព និងការមិនរើសអើង ដូចដែលបានទទួលស្គាល់ក្នុងសេចក្ដីប្រកាសរបស់អង្គការអន្តរជាតិខាងការងារស្ដីពី គោលការណ៍ជាមូលដ្ឋាន និងសិទ្ធិនៅកន្លែងធ្វើការផងដែរ។ ការអនុវត្តនេះគួរធ្វើឡើងស្របតាមច្បាប់ និងគោលការណ៍របស់ប្រទេសគោលដៅផងដែរ។

## ២. គោរពចំពោះ លើការទំនាក់ទំនង ភាពច្បាស់លាស់ និងតម្លាភាពក្នុងការផ្សព្វផ្សាយពាណិជ្ជកម្ម

២.១ ទីភ្នាក់ងារជ្រើសរើសឯកជនត្រូវធ្វើការផ្សព្វផ្សាយពាណិជ្ជកម្មនិងការជ្រើសរើសពលករ ដោយឆ្លុះបញ្ចាំងពីឱកាសការងារ និងការចំណាយបន្ទាប់បន្សំផ្សេងៗលើការធ្វើទេសន្តរប្រវេសន៍។

២.២ ទីភ្នាក់ងារជ្រើសរើសឯកជនត្រូវសហការជាមួយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធរបស់រដ្ឋាភិបាល ក្នុងការអនុវត្តក្នុងការផ្សព្វផ្សាយពាណិជ្ជកម្មជ្រើសរើសពលករ ដូចមានចែងក្នុងច្បាប់ និងគោលការណ៍ណែនាំដែលមានជាធរមាន។

## ៣. គោរពចំពោះ និងចូលរួមកាត់បន្ថយថ្លៃចំណាយបន្ទាប់បន្សំ និងថ្លៃសេវាសម្រាប់ការធ្វើទេសន្តរប្រវេសន៍

៣.១ ថ្លៃសេវាសម្រាប់ការជ្រើសរើសពលករ ឬចំណាយពាក់ព័ន្ធនានាត្រូវធ្វើឡើង ដោយស្របតាមច្បាប់កំណត់ មិនត្រូវគិតថ្លៃលើស និងគិតថ្លៃសេវាដែលសមស្របនៃអត្ថប្រយោជន៍របស់ពលករ ឬអ្នកស្វែងរកការងារធ្វើ។ ទីភ្នាក់ងារជ្រើសរើសឯកជន នឹងចូលរួមអនុវត្តជាជំហានៗដើម្បីកាត់បន្ថយថ្លៃចំណាយបន្ទាប់បន្សំដែលរាប់រងដោយពលករ និងប្ដេជ្ញាអនុវត្តនូវគំរូចំណាយ ដែលគ្មានការគិតថ្លៃសេវាលើពលករ។

៣.២ លក្ខខណ្ឌក្នុងការជ្រើសរើសពលករ រាប់បញ្ចូលទាំងថ្លៃចំណាយបន្ទាប់បន្សំដោយស្របតាមច្បាប់ និងសមហេតុផល គួរត្រូវបានកំណត់ឱ្យបានច្បាស់លាស់ អាចផ្ទៀងផ្ទាត់បញ្ជាក់បាន និងងាយស្រួលយល់។

៣.៣ ថ្លៃចំណាយបន្ទាប់បន្សំផ្សេងៗទៀតរបស់ពលករ នៅពេលមកដល់ប្រទេសគោលដៅត្រូវបានហាមឃាត់ លើកលែងតែតម្រូវដោយច្បាប់របស់ប្រទេសទទួល។

## ៤. គោរពចំពោះ និងអនុវត្តការជ្រើសរើស នៃកិច្ចសន្យាសេវាកេការងារឱ្យធ្វើ និងកិច្ចសន្យាការងារ

៤.១ កិច្ចសន្យាការងារដែលបានរៀបចំឡើងត្រូវប្រើប្រាស់ខេមរភាសា ភាសាប្រទេសទទួលពលករ និងភាសាអង់គ្លេសដែលពលករងាយយល់បាន ឬជួយពន្យល់បន្ថែមឱ្យបានច្បាស់លាស់ដល់ពលករក្នុងករណីចាំបាច់មុនពេលចេញដំណើរពីប្រទេសប្រភពដើម និងវិធានការនានាដើម្បីទប់ស្កាត់ ការការពារដល់ពលករ ក្នុងការទទួលយកកិច្ចសន្យារង(substitute) ដែលវិធានការនេះ អាចអនុវត្តបានទាំងក្នុងប្រទេសប្រភព និងប្រទេសគោលដៅ។

៤.២ ការយល់ព្រមរបស់ពលករក្នុងការទទួលយកលក្ខខណ្ឌនៃការជ្រើសរើស និងលក្ខខណ្ឌការងារគួរធ្វើឡើងដោយស្ម័គ្រចិត្ត និងដោយពុំមានការបង្ខិតបង្ខំ ឬការបោកបញ្ឆោត។

៤.៣ កិច្ចសន្យាសេវារកការងារឱ្យធ្វើ និងកិច្ចសន្យាការងារត្រូវមានភាពច្បាស់លាស់ និងតម្លាភាពយ៉ាងហោចណាស់រាប់បញ្ចូលព័ត៌មានសំខាន់ៗមួយចំនួនមានដូចជា ប្រភេទនៃការងារ អាស័យដ្ឋានកន្លែងធ្វើការ ព័ត៌មានអំពីលក្ខខណ្ឌការងារ ប្រាក់ឈ្នួល ការធានារ៉ាប់រងសង្គម ស្ថានភាពនៃការរស់នៅ និងនិតិវិធីដាក់ពាក្យបណ្ដឹង ឬនិតិវិធីដោះស្រាយវិវាទ។

៤.៤ កិច្ចសន្យាការងារដែលបានរៀបចំឡើងត្រូវតែមានចែងអំពីលក្ខខណ្ឌឱ្យបានច្បាស់លាស់ និងមិនត្រូវចែងក្នុងលក្ខខណ្ឌទូលាយនោះទេ។

៤.៥ ការទទួលខុសត្រូវក្នុងការលុបកិច្ចសន្យាគប្បីធ្វើឡើងដោយភាគីទាំងពីរ គឺទីភ្នាក់ងារជ្រើសរើសឯកជន និងនិយោជកដើម្បីឱ្យប្រាកដថាភាគីទាំងពីរអនុវត្តកិច្ចសន្យាការងារដែលបានយល់ព្រមដោយពលករទេសន្តរប្រវេសន៍។

## ៥. គោរពចំពោះ និងការការពារទិន្នន័យ និងការរក្សាការសម្ងាត់

៥.១ ទីភ្នាក់ងារជ្រើសរើសឯកជនត្រូវធានាថា រាល់ទិន្នន័យផ្ទាល់ខ្លួនទាំងអស់ដែលបានប្រមូល ទទួលបាន ប្រើប្រាស់ ផ្ទេរឬរក្សាទុក ត្រូវតែរក្សាទុកជាការសម្ងាត់ និងមិនត្រូវផ្តល់ដល់ភាគីទី៣ដោយពុំមានការយល់ព្រមជាមុនជាលាយលក្ខណ៍អក្សរផ្អែកតាមព័ត៌មានត្រឹមត្រូវពីពលករ ឬតំណាងពលករឡើយ លើកលែងតែតម្រូវដោយច្បាប់។

៥.២ ទីភ្នាក់ងារជ្រើសរើសឯកជនមិនត្រូវកត់ត្រាទិន្នន័យផ្ទាល់ខ្លួនរបស់ពលកររាប់បញ្ចូលទាំង រូបថត រូបភាពដែលមិនតម្រូវសម្រាប់ធ្វើការវិនិច្ឆ័យឥរិយាបទរបស់ពលករ ឬសម្រាប់ផ្តល់មុខរបរ ឬការងារដល់ពលករឡើយ លើកលែងតែតម្រូវដោយច្បាប់ និងការកត់ត្រាទិន្នន័យផ្ទាល់ខ្លួនរបស់ពលករនោះ បង្ហាញពីការមិនរើសអើង។

## ៦. គោរពចំពោះ ការទទួលស្គាល់ជំនាញ និងគុណវុឌ្ឍិវិជ្ជាជីវៈ

៦.១ ទីភ្នាក់ងារជ្រើសរើសឯកជន គួរធ្វើការពិចារណាលើគោលនយោបាយ និងការអនុវត្តដែលបង្កើនប្រសិទ្ធភាព តម្លាភាព និងការការពារពលករ នៅក្នុងដំណើរការនៃការជ្រើសរើសនេះ ព្រមទាំងការទទួលស្គាល់ទៅវិញទៅមកយ៉ាងគត់មត់នូវជំនាញ និងគុណវុឌ្ឍិរបស់ពួកគេ។

៦.២ ទីភ្នាក់ងារជ្រើសរើសឯកជនគួរផ្តោតការយកចិត្តទុកដាក់ ជាពិសេសដល់ការទទួលស្គាល់ជំនាញ និងគុណវុឌ្ឍិវិជ្ជាជីវៈរបស់ពលករទេសន្តរប្រវេសន៍ ជាស្ត្រីត្រូវបានទទួលស្គាល់ និងផ្តល់តម្លៃឱ្យ ដើម្បីឱ្យពួកគាត់មានលទ្ធភាពអាចធ្វើការងារបានក្នុងវិស័យផ្សេងៗដែលជាជម្រើសរបស់ពួកគាត់។

## ៧. គោរពចំពោះ និងការផ្តល់ព័ត៌មានទេសន្តរប្រវេសន៍ និងទទួលការណែនាំតម្រង់ទិស មុនពេលចេញដំណើរជាចាំបាច់

៧.១ ទីភ្នាក់ងារជ្រើសរើសឯកជន ត្រូវរៀបចំការបណ្តុះបណ្តាលណែនាំតម្រង់ទិសមុនពេលចេញដំណើរដោយត្រូវប្រើប្រាស់កម្មវិធីសិក្សាដែលបានរៀបចំដោយអង្គការ ILO និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬដោយដៃគូអភិវឌ្ឍផ្សេងទៀតដែលនឹងទទួលបានការអនុម័តពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានលក្ខណៈឆ្លើយតបយេនឌ័រ និងសកម្មភាពតាមរយៈការចូលរួមរបស់ពលករ។

៧.២ ទីភ្នាក់ងារជ្រើសរើសឯកជនត្រូវធានាថាពលករទេសន្តរប្រវេសន៍ទាំងអស់ដែលបានជ្រើសរើស (បុរស និងស្ត្រី) បានរៀនសូត្រអំពីសិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវជាក់លាក់របស់ទីភ្នាក់ងារជ្រើសរើសឯកជនដូចជា ទំនៀមទំលាប់ ប្រពៃណី និងច្បាប់នានាដែលពាក់ព័ន្ធនៅក្នុងប្រទេសគោល

ដៅ និងព័ត៌មានទំនាក់ទំនង ដើម្បីស្វែងរកជំនួយក្នុងករណីដែលពួកគេមានបញ្ហា ឬជួបប្រទះនឹងស្ថានភាពគ្រោះអាសន្នណាមួយ។

៧.៣ ដៃគូរសង្គម ក្រុមស្ត្រី ឬសហជីព គួរអញ្ជើញចូលរួមចំណែកផ្តល់ និងបានទទួលការបណ្តុះបណ្តាលតម្រង់ទិសមុនពេលចេញដំណើរ។

## ៨. គោរពចំពោះ និងការដោះស្រាយវិវាទដោយយន្តការទទួលពាក្យបណ្តឹងពលករទេសន្តរប្រវេសន៍

៨.១ ដោយមិនគិតពីអត្តសញ្ញាណ ឬស្ថានភាពផ្លូវច្បាប់របស់ពួកគេ នៅក្នុងរដ្ឋណាមួយ ពលករទេសន្តរប្រវេសន៍ គប្បីមានលទ្ធភាពប្រើប្រាស់យន្តការទទួលពាក្យបណ្តឹង និងយន្តការដោះស្រាយវិវាទផ្សេងទៀតដោយមិនគិតថ្លៃ មានប្រសិទ្ធិភាព និងសមស្រប ដែលយន្តការនេះគឺស្ថិតនៅក្រោមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងករណីមានការចោទប្រកាន់ពីការរំលោភបំពានលើសិទ្ធិរបស់ពួកគេក្នុងដំណើរការនៃការជ្រើសរើស។

៨.២ ទីភ្នាក់ងារជ្រើសរើសឯកជនគប្បីគាំទ្រជានាឱ្យពលករទេសន្តរប្រវេសន៍ បុរស ស្ត្រី ទទួលបាននូវសេវាយុត្តិធម៌ និងប្រើប្រាស់យន្តការទទួលពាក្យបណ្តឹងពលករទេសន្តរប្រវេសន៍នៅឯប្រទេសគោលដៅផងដែរ។

## ៩. គោរពចំពោះ និងធ្វើប្រតិបត្តិការបញ្ជូនពលករទៅធ្វើការងារនៅក្រៅប្រទេសតែនៅក្នុងកិច្ចព្រមព្រៀងអនុស្សរណៈនៃការយោគយល់គ្នា(MOU)ដែលអនុញ្ញាតដោយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ

៩.១ ទីភ្នាក់ងារជ្រើសរើសឯកជននឹងបញ្ជូនពលករ ទៅក្រៅប្រទេសតែតាមរយៈប្រព័ន្ធអនុស្សរណៈនៃការយោគយល់គ្នា (MOU) ឬតាមប្រព័ន្ធទ្វេភាគីទេសន្តរប្រវេសន៍ផ្លូវការផ្សេងទៀតឬតាមរយៈកំណត់ហេតុការទូត និងលុះត្រាតែមានការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតែប៉ុណ្ណោះ។

៩.២ ទីភ្នាក់ងារជ្រើសរើសឯកជន ត្រូវប្រើប្រាស់តែមធ្យោបាយ ស្របច្បាប់ និងមានសុវត្ថិភាព ដើម្បីបញ្ជូនពលករទៅធ្វើការងារក្រៅប្រទេសតែប៉ុណ្ណោះ។ ទីភ្នាក់ងារជ្រើសរើសឯកជននឹងប្រើប្រាស់តែឯកសារស្របច្បាប់ និងនីតិវិធីស្របច្បាប់តែប៉ុណ្ណោះ ដូចជាទិដ្ឋាការស្នាក់នៅ លិខិតអនុញ្ញាតធ្វើការងារសម្រាប់ឱ្យពលករធ្វើការងារទៅបាន។

## ១០. គោរពចំពោះ និងការការពារសិទ្ធិពលករ ដែលធ្វើការងារនៅប្រទេសគោលដៅ

១០.១ ទីភ្នាក់ងារជ្រើសរើសឯកជន ត្រូវបន្តរក្សាទំនាក់ទំនងជាមួយពលករដោយទៀងទាត់ និងត្រូវដឹងពីស្ថានភាពពលករ នៅក្នុងប្រទេសដែលពួកគេកំពុងបំពេញការងារ សម្របសម្រួលជាមួយដៃគូពាក់ព័ន្ធនៅប្រទេសគោលដៅ និយោជក តំណាងទីភ្នាក់ងារផ្តល់ការងារ និងតំណាងទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជាប្រចាំនៅប្រទេសគោលដៅ ដើម្បីការពារសិទ្ធិស្របច្បាប់ បង្ការឬទប់ស្កាត់មិនឱ្យមានការរើសអើង និងការពារផលប្រយោជន៍របស់ពលករទេសន្តរប្រវេសន៍។

១០.២ ទីភ្នាក់ងារជ្រើសរើសឯកជនត្រូវធានាឱ្យមានការពិនិត្យផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវ ដើម្បីធ្វើការវាយតម្លៃអំពីសញ្ញាគ្រោះថ្នាក់ ហានិភ័យ ការរំលោភបំពាន ការកេងប្រវ័ញ្ច ឬការរើសអើងគ្រប់រូបភាពនៅកន្លែងធ្វើការ។

១០.៣ ទីភ្នាក់ងារជ្រើសរើសឯកជនត្រូវបង្កើតនិតិវិធីស្តង់ដារសីលធម៌ដើម្បីឆ្លើយតបនៅពេលមានករណីរំលោភបំពានសិទ្ធិពលករកើតឡើង។

## ១១. គោរពចំពោះ និងគាំទ្រការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មពលករទេសន្តរប្រវេសន៍

១១.១ ទីភ្នាក់ងារជ្រើសរើសឯកជន ត្រូវសហការជាមួយនឹងនិយោជក និងភ្នាក់ងារពាក់ព័ន្ធដទៃទៀតក្នុងប្រទេសប្រភព និងស្ថានទូត ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ឬទីប្រឹក្សាទទួលបន្ទុកការងាររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងប្រទេសគោលដៅដើម្បីសម្របសម្រួលការវិលត្រឡប់របស់ពលករមកកាន់ប្រទេសកំណើតរបស់ពួកគេវិញឱ្យបានសមស្រប និងមានសុវត្ថិភាពបន្ទាប់ពីកិច្ចសន្យាការងាររបស់ពួកគេអស់សុពលភាព។ ការយកចិត្តទុកដាក់ជាពិសេសចំពោះតម្រូវការរបស់ពលករទេសន្តរប្រវេសន៍ជាស្ត្រីគួរផ្តល់ឱ្យផងដែរ។

១១.២ ទីភ្នាក់ងារជ្រើសរើសឯកជនគួរជួយសម្របសម្រួលពលករ តាមរយៈការបំពេញបែបបទដែលចាំបាច់នានាដើម្បីឱ្យការវិលត្រឡប់របស់ពួកគេ មានភាពនឹងនរនៅក្នុងគ្រួសាររបស់ពួកគេ។

## ១២. គោរពចំពោះ និងធ្វើឱ្យមានសុវត្ថិភាព សេរីភាពនៃការបម្លាស់ទីគ្រប់ដំណាក់កាលការធ្វើទេសន្តរ ប្រវេសន៍

១២.១ ទីភ្នាក់ងារជ្រើសរើសឯកជន និងដៃគូរបស់ពួកគេនៅក្នុងប្រទេសគោលដៅ មិនត្រូវតម្រូវឱ្យពលករទេសន្តរប្រវេសន៍ ឬសមាជិកគ្រួសាររបស់ពួកគេដាក់ប្រាក់តម្កល់ ឬវត្ថុបញ្ចាំដទៃទៀតជាថ្នូរនឹងលក្ខខណ្ឌការងារ ឬការទទួលបានការងារធ្វើឡើយ និងមិនត្រូវដកហូត ឬបែអូស ឬបំផ្លាញឯកសារ

ប្រាក់ឈ្នួល ឬរបស់របរកម្មសិទ្ធិផ្ទាល់ខ្លួនដទៃទៀតរបស់ពលករ ឬក៏ដាក់កំហិតលើសេរីភាពនៃការបំលាស់ទីរបស់ពួកគេឡើយ។

១២.២ ទីភ្នាក់ងារជ្រើសរើសឯកជនមានតួនាទីយ៉ាងសំខាន់ជួយដល់ពលករដែលងាយទទួលរងគ្រោះនៃការដាក់កម្រិតសេរីភាពនៃការបម្លាស់ទី ជាពិសេសពលករធ្វើការងារតាមផ្ទះ ពលករដែលបំពេញការងារនៅតំបន់ឆ្ងាយដាច់ស្រយាលដែលត្រូវធ្វើទំនាក់ទំនងជាមួយពួកគេឱ្យបានទៀងទាត់ និងសេរីភាពនៃការបម្លាស់ទីរបស់ពួកគេគួរត្រូវបានអនុវត្តផងដែរ។